ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ បានប្រព្រឹត្តទៅរយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ នៅវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ដោយបានពិនិត្យពិភាក្សាអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រអាទិភាពទាំង ៦ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ដើម្បីកំណត់ទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២៥ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការយកចិត្តទុកដាក់អនុវត្តអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ចំនួន ១០ចំណុច របស់ **សម្តេចធិបតី** ដែលបានដាក់ឱ្យក្រសួងអនុវត្តនាឱកាសចុះជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ កន្លងមកនេះ ព្រមទាំងកម្មវិធីគោលនយោបាយអាទិភាពចំនួន ២ នៃកម្មវិធីគោលនយោបាយអាទិភាពទាំង ៦ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា គឺ "កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ" និង "ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស."។ ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ និយោជក និងបងប្អូនកម្មករនិយោជិត ដែលបានរួមគ្នាប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយសម្រេចបាននូវលទ្ធផលជោគជ័យគួរជាទីមោទនៈ ដូចខាងក្រោមៈ

## I- លទ្ធផលការងារសំខាន់ៗ ដែលសម្រេចបាន

### ១. ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម

- បានរៀបចំអង្កេតស្តីពី "តម្រូវការជំនាញរបស់និយោជក ឆ្នាំ២០២៤" និង "ទស្សនវិស័យការងារកម្ពុជា ឆមាសទី២ ឆ្នាំ២០២៤" បានរៀបចំព្រឹត្តិបត្រទស្សនវិស័យមុខរបរ និងការងារចំនួន ២ គឺឆមាសទី១ និង



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ធមាសទី២ ឆ្នាំ២០២៤ និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីព្រឹត្តិបត្រ "ទស្សនវិស័យមុខរបរ និងការងារ តម្រូវការជំនាញ និងការងារសម្រាប់យុវជន", របាយការណ៍លទ្ធផលអង្កេតស្តីពី "តម្រូវការជំនាញរបស់និយោជក ឆ្នាំ២០២៤" និង ៣ទស្សនវិស័យការងារកម្ពុជា ធមាសទី២ ឆ្នាំ២០២៤" ដែលជួយឱ្យសាធារណជន សិស្ស និស្សិត និងនិយោជក អាចទទួលព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយអំពីព័ត៌មានទីផ្សារការងារ តម្រូវការកម្លាំងពលកម្ម និងនិន្នាការប្រាក់ឈ្នួលតាមវិស័យ និងបានចេញផ្សាយកម្លាំងពលកម្មប្រចាំសប្តាហ៍ ប្រចាំខែ និងចុះឈ្មោះស្វែងរកការងារធ្វើនៅតាមសាកលវិទ្យាល័យ ទីប្រជុំជន និងផ្សារទំនើប

- បានរៀបចំសន្និសីទថ្នាក់ជាតិស្តីពីសេដ្ឋកិច្ចទីផ្សារការងារលើប្រធានបទ "ការងើបឡើងវិញនៃសេដ្ឋកិច្ច និងការងារ និងដំណើរឆ្ពោះទៅកាន់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច" ក្នុងគោលបំណងជំរុញកិច្ចសហការផ្លាស់ប្តូរចំណេះដឹង និងនវានុវត្តន៍ ការស្វែងយល់ពីបញ្ហាប្រឈម និងឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនៃទីផ្សារការងារតាមរយៈកិច្ចពិភាក្សា និងការចែករំលែកចំណេះដឹង
- បានពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងការរៀបចំវេទិកាការងារដោយបានចុះឈ្មោះអ្នកស្វែងរកការងារសរុបចំនួន ៥០ ៤៩៤នាក់, បញ្ជូនទៅនិយោជកចំនួន ៩៤ ៩០០ដង/នាក់, និងជួយស្វែងរកការងារជូនប្រជាពលរដ្ឋបានជិត ១ម៉ឺនកន្លែង និងបានផ្តល់ជម្រើសឱកាសការងារនៅក្រៅប្រទេសចំនួន ៤៤ ៨៦២នាក់
- បានរៀបចំវេទិកាការងារចំនួន ៦៦ដង មានអ្នកចូលរួមចំនួន ១០ ២២៤នាក់ (ស្រី ៤ ៧១៣នាក់)
- បានរៀបចំពិព័រណ៍ការងារថ្នាក់ជាតិ និងរាជធានី ខេត្តសរុបចំនួន ៣ដង ដែលមានអ្នកចូលរួមចំនួន ៤៧ ៩៨១នាក់ (ស្រី ២២ ២៣៤នាក់) និងអ្នកចូលរួមទស្សនាតាមប្រព័ន្ធអនឡាញចំនួន ៧៣ ៩៣៣ដង ព្រមទាំងបានរៀបចំពិព័រណ៍ចល័តចំនួន ៩២៤ដង អ្នកចូលរួមចំនួន ៦៩ ៦០៨នាក់ (ស្រី ៣៩ ៥២៩នាក់)
- បានបង្កិតមធ្យោបាយផ្តល់សេវា ដោយបានបង្កើតសាខាមជ្ឈមណ្ឌលការងារចំនួន ៣ នៅផ្សារទំនើបអ៊ីអនម៉ល និងបច្ចុប្បន្នមានមជ្ឈមណ្ឌលការងារចំនួន ១៤, មជ្ឈមណ្ឌលការងារចល័តចំនួន ៧ និងបញ្ជរសេវាសាធារណៈចល័តតាមប្រព័ន្ធអេឡិចត្រូនិកចំនួន ១០០គ្រឿង
- បានផ្តល់ការណែនាំ និងប្រឹក្សាយោបល់ អាជីព ការងារ និងវិជ្ជាជីវៈ ទៅដល់ សិស្ស និស្សិត អ្នកស្វែងរកការងារធ្វើ និងកម្មករនិយោជិត សរុបចំនួន ៤៥ ៨៤០នាក់ (ស្រី ២៣ ០៨០នាក់)
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់ផលិតភាព និងសហគ្រិនភាព ដល់សិស្ស និស្សិត អ្នកស្វែងរកការងារ និងកម្មករនិយោជិតចំនួន ៥៣វគ្គ អ្នកចូលរួមចំនួន ១ ៨៣៤នាក់ (ស្រី ១ ០៤៥នាក់)។

Follow us Follow us Follow us Follow us

**សូមស្កេនដើម្បីទទួលបានព័ត៌មានស្តីពីឱកាសការងារ**

សេវាសាធារណៈរបស់ក្រសួង

**MLVT Services**

## ២. ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានបន្តអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពបន្ថែមចំនួន ៣៤គុណវុឌ្ឍិ លើ ២១មុខជំនាញ និងបានអភិវឌ្ឍកញ្ចប់សិក្សាផ្អែកលើសមត្ថភាពបានចំនួន ១៤០មេរៀន លើ ៧គុណវុឌ្ឍិ (C1) នៃ ៧មុខជំនាញ លើវិស័យអាទិភាពទាំង ៥ រួមមាន វិស័យសំណង់, មេកានិកទូទៅ/មេកានិករថយន្ត, ធុរកិច្ចនិងព័ត៌មានវិទ្យា, ទេសចរណ៍, និងកសិកម្ម និងកសិ-ឧស្សាហកម្ម។ បើគិតមកដល់បច្ចុប្បន្ននេះ ក្រសួងបានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពបានចំនួន ២២២គុណវុឌ្ឍិ លើ ៩៦មុខជំនាញ និងបានអភិវឌ្ឍកញ្ចប់សិក្សាផ្អែកលើសមត្ថភាព បានចំនួន ១ ៩៧៩មេរៀន លើ ៤៥គុណវុឌ្ឍិ (C1) នៃ ៤៥មុខជំនាញ លើវិស័យអាទិភាពទាំង ១០ រួមមាន វិស័យសំណង់, អគ្គិសនីនិងថាមពល, អេឡិចត្រូនិក, កម្មន្តសាល, មេកានិកទូទៅ/មេកានិករថយន្ត, ធុរកិច្ចនិងព័ត៌មានវិទ្យា, សេវាកម្ម, បរិក្ខារត្រជាក់និងកម្តៅ, ទេសចរណ៍, និងកសិកម្ម និងកសិ-ឧស្សាហកម្ម ក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- បានធ្វើវិក្រឹតការគ្រូបច្ចេកទេសសរុបចំនួន ៨៤១នាក់ (ស្រី ១២២នាក់) ក្នុងនោះ គ្រូបច្ចេកទេសចូលរួមសិក្ខាសាលា/វគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន ១១១នាក់ (ស្រី ១៥នាក់), គ្រូបច្ចេកទេសលើសមត្ថភាពជំនាញតាមកម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ (RIS) ចំនួន ៣២៤នាក់ (ស្រី ៣៥នាក់), គ្រូបច្ចេកទេសក្នុងការប្រើប្រាស់វិធីសាស្រ្តបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) ចំនួន ២០៦នាក់ (ស្រី ២៧នាក់) និងបានពង្រឹងសមត្ថភាព និងគុណភាពគ្រូបច្ចេកទេសឌីជីថល និងឧស្សាហកម្ម ៤.០ ចំនួន ២០០នាក់ (ស្រី ៤៥នាក់)
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅក្រោមឱវាទក្រសួងចំនួន ២៥៣ ក្នុងនោះ គ្រឹះស្ថានសាធារណៈចំនួន ៣៧ និងគ្រឹះស្ថានឯកជន និងអង្គការ/សមាគមចំនួន ២១៦ បានបញ្ចប់ការបណ្តុះបណ្តាលសិក្ខាកាម សិស្ស និស្សិត សរុបចំនួន ៤៩ ៦៨៣នាក់ (ស្រី ២១ ១៥១នាក់) ក្នុងនោះ បរិញ្ញាបត្របច្ចេកទេសចំនួន ៨ ០០៨នាក់ (ស្រី ៣ ០២៨នាក់) សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសចំនួន ៦ ០០៤នាក់ (ស្រី ២ ២៤១នាក់) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (C3) ចំនួន ១ ២១២នាក់ (ស្រី ៣៣៤នាក់) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (C2) ចំនួន ១ ៦១៦នាក់ (ស្រី ៤៦៨នាក់) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) ចំនួន ១៧ ៥៣២នាក់ (ស្រី ៦ ២៨១នាក់) វិញ្ញាបនបត្រវិជ្ជាជីវៈចំនួន ១៥ ៣១១នាក់ (ស្រី ៨ ៧៩៩នាក់
- បានខិតខំអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅចំនួន ១,៥លាននាក់ មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដោយគិតត្រឹមឆ្នាំ២០២៤ នេះ ក្រសួងបានចុះឈ្មោះអ្នកស្នើសុំចូលរៀនចំនួន ៨៥ ៦៣៩នាក់ និងមានសិស្សកំពុងសិក្សា និងបានបញ្ចប់សរុប

ចំនួន ៤៥ ២៧០នាក់។ យុវជន សិស្ស និងនិស្សិត អាចចុះឈ្មោះ, ទាញយកកម្មវិធីទូរសព្ទដៃ និងឯកសារមេរៀននៃកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស តាមរយៈ QR Code ខាងក្រោម៖

**ប្រព័ន្ធឌីជីថលសម្រាប់កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស**
**ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ**

ចុះឈ្មោះតាមគេហទំព័រ ទាញយកកម្មវិធីទូរសព្ទ ឯកសារមេរៀន

- បានហ្វឹកហ្វឺនកូនជាងចំនួន ៣៨ ៨៤៦នាក់ (ស្រី ២៦ ២៩៦នាក់) និងបានធ្វើតេស្តកូនជាង និងផ្តល់វិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាងចំនួន ៣៤ ១៦៥នាក់ (ស្រី ២៣ ០៣៨នាក់)
- បានចុះបញ្ជិកាទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពនៃគ្រឹះស្ថាន អ.ប.វ. ចំនួន ៧ ដែលធ្វើឱ្យមានមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពសរុបចំនួន ១៥, បានបណ្តុះបណ្តាលអ្នកគ្រប់គ្រងមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពចំនួន ១៣នាក់ (ស្រី ២នាក់) និងបានបណ្តុះបណ្តាលគ្រូ/អ្នកបច្ចេកទេសឱ្យក្លាយជាអ្នកវាយតម្លៃសមត្ថភាពចំនួន ៤៤នាក់ (ស្រី ៦នាក់)
- បានបើកច្រកសិក្សាកាន់តែទូលំទូលាយ សម្រាប់ការទទួលបានការសិក្សាពេញមួយជីវិត តាមរយៈកម្មវិធីស្ពានចម្លងបន្តជំនាញ និងកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណិត សម្រាប់អ្នកដែលបោះបង់ចោលការសិក្សា សិស្សបញ្ចប់ថ្នាក់ស្ពានចម្លងបន្តជំនាញ ព្រមទាំងបានបើកច្រកក្នុងការទទួលស្គាល់ជំនាញដល់កម្លាំងពលកម្មដែលមានជំនាញ តាមរយៈការធ្វើតេស្តទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL/RCC)
- បានទទួលចុះបញ្ជីវិស្វករក្នុងឆ្នាំ២០២៤ សរុបចំនួន ៩៤៤នាក់ (ស្រី ៥០នាក់) ក្នុងនោះ វិស្វករជាតិចំនួន ៩៤២នាក់ (ស្រី ៥០នាក់) និងវិស្វករបរទេសចំនួន ២នាក់។ គិតមកត្រឹមឆ្នាំ២០២៤ នេះ បានចុះបញ្ជីវិស្វករសរុបចំនួន ៨ ៨៤៨នាក់ (ស្រី ៣៦៦នាក់) ក្នុងនោះ វិស្វករជាតិចំនួន ៨ ៧៣១នាក់ (ស្រី ៣៦៤នាក់) និងវិស្វករបរទេសចំនួន ១១៧នាក់ (ស្រី ២នាក់)។

**៣. ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ**

- បានយកចិត្តទុកដាក់អនុវត្ត និងតាមដានជាប្រចាំនូវអនុសាសន៍ទាំង ១០ចំណុច របស់ **សម្តេចធិបតី** និងបានបើកវគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពបុគ្គលិកទទួលបន្ទុកផ្នែករដ្ឋបាលសរុបចំនួន ១ ០៥៥នាក់, ថ្នាក់ដឹកនាំសហជីពមូលដ្ឋានចំនួន ១ ២៤២នាក់ និងមន្ត្រីអធិការកិច្ចការងារចំនួន ១ ៥២១នាក់ ព្រមទាំងមន្ត្រីរាជការនិងគ្រូបង្គោលចំនួន ១ ០៣៦នាក់ ក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ ធានាបាននូវសង្គតិភាពក្នុងការបកស្រាយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងពង្រឹងប្រព័ន្ធអធិការកិច្ចការងារ ដោយបានសហការជាមួយក្រសួងយុត្តិធម៌ផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់អធិការការងារ សរុបចំនួន ២៥៩ រូប

- បានជានាំនូវការគោរពលក្ខខណ្ឌការងាររបស់សហគ្រាស គ្រឹះស្ថាន ដោយបានធ្វើអធិការកិច្ចការងារនៅតាមសហគ្រាស គ្រឹះស្ថានដោយផ្ទាល់ និងតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ១០ ៤៨៤លើក, ដាក់កំហិតចំនួន ៣០០សហគ្រាស និងបានចេញលិខិតផាកពិន័យចំនួន ១៣២សហគ្រាស ដែលប្រការនេះបានជំរុញឱ្យសហគ្រាស គ្រឹះស្ថាន គោរពច្បាប់ស្តីពីការងារកាន់តែច្រើន និងមានអត្រាអនុលោមភាពខ្ពស់ និងបានរៀបចំក្រុមអធិការកិច្ចអន្តរក្រសួងចំនួន ៧ក្រុម ដែលមានសមាសភាពមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងបរិស្ថាន, ក្រសួងទេសចរណ៍, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់ចុះអធិការកិច្ចរួមគ្នាតែ ១ដង/ឆ្នាំ ស្របតាមគោលការណ៍ដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាស្ថាប័នដឹកនាំ ដោយនៅត្រឹមឆ្នាំ២០២៤ នេះ ក្រុមអធិការកិច្ចអន្តរក្រសួងបានចាប់ផ្តើមចុះអធិការកិច្ចនៅក្នុងវិស័យកម្មន្តសាល បានចំនួន ១១៨សហគ្រាស
- សហគ្រាស គ្រឹះស្ថាន បានកើនឡើងពីចំនួន ៤០ ៩៧៥ នៅឆ្នាំ២០២៣ ដល់ចំនួន ៤៤ ៧៩៨សហគ្រាស នៅឆ្នាំ២០២៤ នេះ (កើនឡើងចំនួន ៣ ៨២៣សហគ្រាស) ហើយចំនួនកម្មករនិយោជិត បានកើនឡើងពីចំនួន ១ ៧១៥ ០២៩នាក់ ដល់ចំនួន ១ ៨១៦ ០៤៦នាក់ (កើនឡើងចំនួន ១០១ ០១៧នាក់) ដែលបានផ្តល់ប្រាក់ឈ្នួលមធ្យមសរុបប្រចាំឆ្នាំ ប្រមាណ ៥,៦៣ន់លានដុល្លារអាម៉េរិក
- បានដំឡើងប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០២៥ ជូនដល់បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលមានចំនួន ២០៦ដុល្លារអាម៉េរិក និងបន្ថែម ២ដុល្លារអាម៉េរិក ដែល **សម្តេចធិបតី** បានផ្តល់ជូន នាំឱ្យប្រាក់ឈ្នួលអប្បបរមាបានកើនដល់ ២០៨ដុល្លារអាម៉េរិក បើបូករួមប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាបបំផុតចន្លោះពី ២២៥ដុល្លារអាម៉េរិក ដល់ ២៣៦ដុល្លារអាម៉េរិកក្នុង ១ខែ
- បានពន្យល់ណែនាំសហគ្រាស គ្រឹះស្ថាន អំពីការកសាងទារកដ្ឋាន ដោយមានសហគ្រាស ចំនួន ៣ បានស្ម័គ្រចិត្តសាងសង់ទារកដ្ឋានរបស់ខ្លួន ក្នុងនោះ៖
    ១.រោងចក្រ ម៉ាវ៉ែល ហ្គាមិន ឯ.ក (Marvel Garment Co., Ltd) ស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ រ៉ូយ៉ាល់ គ្រុប ភ្នំពេញ បានសាងសង់រួចរាល់ និងគ្រោងសម្ពោធដាក់ឱ្យដំណើរការនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ នេះ ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។
    ២.រោងចក្រ អ៊ីលីថិច (EALYTEX (Cambodia) Garment Co., Ltd) បានចាប់ផ្តើមសាងសង់នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥ នេះ។
    ៣.រោងចក្រ តារាល អ៊ិនធើណេសិនណល ឯ.ក (TARAL INTERNATIONAL Co., Ltd) នៅខេត្តកំពង់ស្ពឺ កំពុងពិភាក្សាក្នុងការសាងសង់ ដែលអាចត្រៀមចាប់ផ្តើមសាងសង់ ឆ្នាំ២០២៥ នេះ។
    ដោយឡែកក្នុងឆ្នាំ២០២៥ នេះ នឹងមានរោងចក្រមួយចំនួនផ្សេងទៀត ដែលនឹងស្ម័គ្រចិត្តបំពេញនូវកាតព្វកិច្ចទំនួលខុសត្រូវសង្គម និងលក្ខខណ្ឌការងារចូលរួមក្នុងការកសាងមណ្ឌលមើលថែរក្សាទារកបន្ថែមទៀតផងដែរ។

- បានដាក់ឱ្យអនុវត្តនូវការជ្រើសរើសពានរង្វាន់ "សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ប្រចាំឆ្នាំ២០២៥" ដោយផ្អែកលើលក្ខណវិនិច្ឆ័យអនុលោមភាពចំនួន ៨ និងកំណត់យកថ្ងៃទី១ ខែឧសភា ជាថ្ងៃប្រគល់ពានរង្វាន់ជារៀងរាល់ឆ្នាំ
- បានបន្តលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ និងបើកទូលាយអនុលោមតាមច្បាប់ស្តីពីសហជីព និងបទដ្ឋានការងារអន្តរជាតិ ដោយបានចុះបញ្ជិកាអង្គការវិជ្ជាជីវៈថ្មីសរុបចំនួន ២៣៩ ជាសហជីពមូលដ្ឋាន ដែលធ្វើឱ្យអង្គការវិជ្ជាជីវៈបានកើនដល់ ៦ ៥១១ នៅឆ្នាំ២០២៤ ក្នុងនោះ សហភាពសហជីពមានចំនួន ៤២, សហព័ន្ធសហជីពមានចំនួន ២៨០, សហជីពមូលដ្ឋានមានចំនួន ៦ ១៧៧, និងសមាគមនិយោជកមានចំនួន ១២
- បានពង្រឹងយន្តការដោះស្រាយវិវាទការងារ ដោយបានធ្វើឱ្យអត្រាដោះស្រាយសះជាវិវាទការងាររួម ទាំងកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាលកើនដល់អត្រាប្រមាណ ៨៧,៣២% ដែលឆ្លុះបញ្ចាំងឱ្យឃើញពីភាពចាស់ទុំនៃតួអង្គពាក់ព័ន្ធ និងប្រសិទ្ធភាពនៃយន្តការផ្សះផ្សាវិវាទការងារក្រៅប្រព័ន្ធតុលាការ ព្រមទាំងសមត្ថភាពប្រកបដោយវិជ្ជាជីវៈរបស់មន្ត្រីផ្សះផ្សាវិវាទការងារ និងបានអន្តរាគមន៍ដោះស្រាយបញ្ហាកូដកម្មសរុបចំនួន ១២៣ករណី និងបានធ្វើអន្តរាគមន៍ដោះស្រាយបញ្ហាបាតុកម្មចំនួន ៥ករណី
- បានបន្តលើកកម្ពស់ការយល់ដឹងស្តីពីការបង្ការ និងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារតាមរយៈការផ្សព្វផ្សាយគោលការណ៍ណែនាំ និងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារកុមារ និងពលកម្មតាមរយៈយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម, វេទិកាសាធារណៈ និងសិក្ខាសាលា-កិច្ចប្រជុំផ្សព្វផ្សាយនានា សរុបចំនួន ៣១២លើក មានអ្នកចូលរួមសរុបចំនួន ៨ ៤៤៥នាក់ (ស្រី ៣ ៥៩០នាក់) និងបានបង្កើនការត្រួតពិនិត្យការអនុញ្ញាតលើការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងស្របតាមច្បាប់ស្តីពីការងារ
- បានបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងសុខភាពការងារសម្រាប់និយោជក និងកម្មករនិយោជិតចំនួន ១២៥វគ្គ មានសិក្ខាកាមចំនួន ២ ៦៤៧នាក់ (ស្រី ១ ៤២៧នាក់) និងបានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងសុខភាពការងារ ជាពិសេស ផលប៉ះពាល់នៃគ្រឿងញៀន និងជំងឺអេដស៍ចំនួន ១៤២លើក ដោយមានអ្នកចូលរួមសរុបចំនួន ២៣ ៧៥៦នាក់ (ស្រី ១៣ ៨៩៦នាក់)។

## ៤. ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព

- បានសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ ធ្វើអធិការកិច្ចហត្ថពលកម្មបរទេសបានចំនួន ៤ ៦៥២សហគ្រាស ដើម្បីកាត់បន្ថយការជួញដូរមនុស្ស និងការឆបោកមកធ្វើការនៅក្នុងប្រទេស, បានរៀបចំខិតបណ្ណស្តីពីនីតិវិធីសម្រាប់ជនបរទេសចូលមកធ្វើការនៅកម្ពុជា ចំនួន ៦ភាសា ដូចជា ខ្មែរ អង់គ្លេស ចិន ជប៉ុន ហិនឌី និងបង់ក្លាដេស ព្រមទាំងបានជូនដំណឹងអំពីខិតបណ្ណនេះទៅដល់គ្រប់ស្ថានទូតពាក់ព័ន្ធដើម្បីផ្សព្វផ្សាយទៅដល់ប្រជាជនរបស់ខ្លួន

- បានបន្តពង្រឹងយន្តការគ្រប់គ្រងហត្ថពលកម្មបរទេសដោយជំរុញការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីធ្វើការដោយស្របច្បាប់របស់ជនបរទេសនៅកម្ពុជាដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងភាគីពាក់ព័ន្ធ និងបានចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេសតាមបណ្តាសហគ្រាស គ្រឹះស្ថានគោលដៅ ដោយបានដាក់កំហិតនិងផាកពិន័យចំពោះការប្រើប្រាស់ហត្ថពលកម្មបរទេសខុសនីតិវិធី
- បានស្វែងរកឱកាសការងារជូនប្រជាពលរដ្ឋនៅក្រៅប្រទេសចំនួន ៤៤ ៨៦២នាក់ (ស្រី ១៧ ២៧០នាក់) និងមានពលករកម្ពុជាបានធ្វើមាតុភូមិនិវត្តន៍ចំនួន ១៨ ៥៦១នាក់ (ស្រី ៦ ៩៣៤នាក់) ដែលធ្វើឱ្យពលករកម្ពុជាដែលបាននិងកំពុងស្នាក់នៅ និងធ្វើការនៅបរទេស បានកើនឡើងពីប្រមាណ ១,៣៥លាននាក់ នៅឆ្នាំ២០២៣ ដល់ប្រមាណ ១,៣៨លាននាក់ នៅឆ្នាំ២០២៤ ធ្វើឱ្យប្រាក់បញ្ញើត្រឡប់មកប្រទេសវិញ បានកើនពីប្រមាណ ២,៩៤៣ន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣ ដល់ប្រមាណ ២,៩៥៣ន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៤
- បានបន្តពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព ព្រមទាំងគាំទ្រ និងការពារសិទ្ធិនិងផលប្រយោជន៍ ក៏ដូចជាសម្រាលបន្ទុករបស់បងប្អូនពលករកម្ពុជាដែលធ្វើការនៅបរទេស ដោយបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយធនាគារចំនួន ៨ ក្រោមសក្ដីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដែលជួយសម្រួលដល់ការទទួលបានប្រាក់កម្ចីផ្លូវការតាមការស្ម័គ្រចិត្ត និងកាត់បន្ថយបន្ទុកចំណាយការប្រាក់របស់ពលករទេសន្តរប្រវេសន៍ពីអត្រាកម្ចី ១៨% មកត្រឹម ៨,៥% ក្នុងមួយឆ្នាំ ឬ ០,៧១% ក្នុងមួយខែ ដើម្បីឱ្យបងប្អូនពលករមានស្ថិរភាពសេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយភាពតានតឹងផ្នែកហិរញ្ញវត្ថុ និងបានបង្កើតក្រុមតេឡេក្រាម https://t.me/KhmerMigrantWorker ដើម្បីជាជំនួយដល់បងប្អូនពលករទេសន្តរប្រវេសន៍

“សម្រាប់ពលករទេសន្តរប្រវេសន៍”

- បានកំណត់តម្លៃសេវាបញ្ជូនអតិបរមាសម្រាប់ការធ្វើទេសន្តរប្រវេសន៍ការងារទៅប្រទេសថៃ (តម្លៃ ៥០០ ដុល្លារអាម៉េរិក) និងប្រទេសជប៉ុន (តម្លៃ ៥ ០០០ដុល្លារអាម៉េរិក) និងបានរៀបចំកិច្ចប្រជុំទ្វេភាគីស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ជាមួយក្រសួង ស្ថាប័ននៃប្រទេសទទួល ដូចជា ថៃ និងជប៉ុន
- បានសម្របសម្រួលជាមួយភាគីថៃកាត់បន្ថយតម្លៃស្នើសុំទិដ្ឋាការការងារថ្មីពី ២ ០០០បាត និងតម្លៃស្នើសុំបន្តសុពលភាពឡើងវិញពី ១ ៩០០បាត មកត្រឹម ៥០០បាតដូចគ្នា សម្រាប់រយៈពេល ៤ឆ្នាំ ចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៧ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋខ្មែរ និងពលករកម្ពុជាដែលមានបំណងទៅធ្វើការ និងកំពុងធ្វើការនៅប្រទេសថៃ
- បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធតាមដានពលករទេសន្តរប្រវេសន៍ (Tracking System) ដើម្បីឱ្យពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសារអាចតាមដានដំណើរឯកសារបានដោយខ្លួនឯង ចាប់ពីដំណាក់កាលចុះឈ្មោះស្វែងរកការងាររហូតដល់ចប់កិច្ចសន្យាការងារ និងវិលត្រឡប់មកប្រទេសកម្ពុជាវិញ តាមរយៈគេហទំព័រ https://tracking.ocwc.co

“ប្រព័ន្ធតាមដាន”

- បានចាត់តាំងអនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល នៅប្រទេសដែលមានពលករកម្ពុជាធ្វើការមានចំនួន ៤ប្រទេស ដូចជា សាធារណរដ្ឋកូរ៉េ ២រូប ប្រទេសថៃ ៣រូប ប្រទេសម៉ាឡេស៊ី ២រូប និងប្រទេសជប៉ុន ១រូប ដើម្បីសម្របសម្រួលអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ពលករដែលកើតមានឡើងក្នុងពេលបំពេញការងារ និងការពារផលប្រយោជន៍ពលករកម្ពុជា ព្រមទាំងលើកកម្ពស់ការស្វែងរកឱកាសការងារសម្រាប់ពលករ។

## ៥. ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្ត នៃស្ថានភាពសង្គម-សេដ្ឋកិច្ច

- បានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមសម្រាប់បុគ្គលស្វ័យនិយោជន៍ដោយរលូន និងបានបង្កើនការចុះឈ្មោះសមាជិកថ្មីផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច និងតាមរបបភាគទានដោយស្ម័គ្រចិត្ត សរុបចំនួន ៨៨០ ២៣៦នាក់ (ស្រី ៤៧០ ០២១នាក់) ក្នុងនោះ សមាជិកតាមរបបភាគទានជាកាតព្វកិច្ចចំនួន ៣៤៧ ៧៦៧នាក់ (ស្រី ១៥០ ៩៧៨នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន ៥៣២ ៤៦៩នាក់ (ស្រី ៣១៩ ០៤២នាក់) ដែលធ្វើឱ្យសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ច និងតាមរបបភាគទានដោយស្ម័គ្រចិត្ត កើនដល់ចំនួន ២ ៧១៥ ០៨៤នាក់ (ស្រី ១ ៥០៣ ៩០៧នាក់) ក្នុងនោះ តាមរបបភាគទានជាកាតព្វកិច្ចចំនួន ២ ០៧៩ ២៨៥នាក់ (ស្រី ១ ១២១ ៤៤១នាក់) និងតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន ៦៣៥ ៧៩៩នាក់ (ស្រី ៣៨២ ៤៦៦នាក់)។ នៅឆ្នាំ២០២៤ នេះ មានសមាជិកប្រើប្រាស់សេវាមូលដ្ឋានសុខាភិបាលសរុបចំនួន ៧ ៧៧៣ ៧៩៩ ដង.នាក់ ដោយចំណាយថវិកាអស់ចំនួន ៦៥០ ២៣៦លានរៀល (ប្រមាណ ១៥៧,៥លានដុល្លារអាមេរិក)
- បានផ្តល់របបសន្តិសុខសង្គមដល់ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៣៧សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ១៣៥ ០០២នាក់
- បានដាក់ឱ្យដំណើរការប្រព័ន្ធស្កេនមេដៃ និងប្រព័ន្ធតាមដានគ្រប់គ្រងករណីការចូលប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលជាដៃគូ ប.ស.ស. ដែលធ្វើឱ្យការគ្រប់គ្រងការប្រើប្រាស់សេវានៅតាមមូលដ្ឋានសុខាភិបាលមានប្រសិទ្ធភាពជាងមុន ព្រមទាំងបានកែទម្រង់ប្រព័ន្ធទូទាត់ថ្លៃចំណាយការប្រើប្រាស់នៅតាមមូលដ្ឋានសុខាភិបាលទាំងរដ្ឋ និងឯកជនបានលឿនជាងមុន
- បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលថ្មីចំនួន ៦៦ ដោយគិតមកត្រឹមឆ្នាំ២០២៤ នេះ បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំងរាជធានី ខេត្ត សរុបចំនួន ១ ៥៩៥ ក្នុងនោះមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ១ ៤៣១ និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ១៦៤
- បានបើកផ្តល់ប្រាក់ឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាលសម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១២៤ ៨១២នាក់ និងកូនចំនួន ១២៣ ៦៦៣នាក់ ដោយចំណាយថវិកាអស់ប្រមាណ ១០៦ ៤០១លានរៀល។ គិតត្រឹមឆ្នាំ២០២៤ នេះ បានឧបត្ថម្ភថវិកាដល់ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំសរុបចំនួន ៥៧៣ ៨៨៩នាក់ មានកូនចំនួន ៥៦២ ០៥៩នាក់ ចំណាយថវិកាសរុបប្រមាណ ២៩៦ ៥៦៧លានរៀល

- បានរៀបចំដាក់ឱ្យអនុវត្តការចុះបញ្ជីសហគ្រាស សមាជិក និងការបង់ភាគទានតាមប្រព័ន្ធអនឡាញ (https://enterprise.nssf.gov.kh) និងដាក់ឱ្យដំណើរការការចុះបញ្ជីបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. តាមរយៈកម្មវិធីទូរសព្ទដៃ NSSF Member App

“NSSF Member App”

Download on the App Store

GET IT ON Google Play

- ក្រសួងបានដាក់ឱ្យដំណើរការប្រអប់បណ្តឹងអនាមិក ដើម្បីផ្តល់ភាពងាយស្រួលដល់សមាជិក ប.ស.ស. និងម្ចាស់មូលដ្ឋានសុខាភិបាលក្នុងការទទួលបានការឆ្លើយតបរបស់ក្រសួងនូវចម្ងល់ ឬភាពមិនពេញចិត្ត ឬភាពមន្ទិលសង្ស័យ ឬប្តឹងបុគ្គលណាមួយដោយពុំមានតម្រូវឱ្យបង្ហាញអត្តសញ្ញាណរបស់ម្ចាស់បណ្តឹងតាមរយៈគេហទំព័រ https://feedback.mlvt.gov.kh ឬអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម និងបានបន្ថែមមន្ត្រីដែលកាន់ប្រព័ន្ធទាន់ហេតុការណ៍ដោយបានប្រតិបត្តិការការងារ និងបម្រើសេវាកម្មផ្ទាល់ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ពីម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ១៧:៣០នាទីល្ងាច រីឯស្នាក់ការកណ្តាលបម្រើសេវាកម្មផ្ទាល់ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ២២:០០នាទីយប់ និងមានបម្រើសេវាអតិថិជនពេញ ២៤ម៉ោង លើ ៧ថ្ងៃ តាមរយៈប្រព័ន្ធ Hotline លេខ ១២៩៧ និង ១២៨៦ សម្រាប់ទទួលការហៅចូលដើម្បីសាកសួរព័ត៌មានអំពីរបបសន្តិសុខសង្គម ការឆ្លើយតបនូវសំណួររបស់សាធារណជន រួមទាំងទទួលបណ្តឹងតវ៉ាផ្សេងៗ

“បណ្តឹងអនាមិក”

- ការដាក់ឱ្យដំណើរការប្រព័ន្ធ Tracking System ដើម្បីជួយសម្រួលការតាមដានការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល និងការស្នើសុំការទូទាត់។

“ប្រព័ន្ធតាមដានការចុះកិច្ចព្រមព្រៀងជាមួយ
មូលដ្ឋានសុខាភិបាល និងការស្នើសុំការទូទាត់”

### ៦. ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ

- បានបន្តលើកកម្ពស់វិធានការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន ពិនិត្យ និងវិភាគមុខងារ រចនាសម្ព័ន្ធឡើងវិញ ស្របតាមវិធានការគន្លឹះក្នុងការជំរុញកំណែទម្រង់រដ្ឋបាលសាធារណៈ និងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា
- បានធ្វើឌីជីថលនីយកម្មការគ្រប់គ្រងវត្តមានតាមរយៈការស្កេនមុខ ផ្អែកតាមបំណែងចែកវេនការងារ និងដាក់ឱ្យអនុវត្តនៅទីស្តីការក្រសួង គ្រឹះស្ថាន អ.ប.វ. សាធារណៈក្រោមឱវាទក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត

- បានជំរុញកំណែទម្រង់រដ្ឋបាលសាធារណៈ និងបានដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល (DMS) នៅថ្នាក់កណ្តាលចំនួន ២៩អង្គភាព
- បានជំរុញបរិវត្តកម្មឌីជីថល ដើម្បីធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ តាមរយៈការដាក់ឱ្យអនុវត្តថ្នាលបច្ចេកវិទ្យាឌីជីថល ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង និងបានដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត និងបានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបញ្ជូនសារខ្លីទៅលេខទូរសព្ទ (Push Message) ដូចជា (១) កម្មវិធីអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស, (២) របបសន្តិសុខសង្គម, (៣) ឱកាសការងារ, (៤) ការហាមឃាត់ការប្រើប្រាស់ពលកម្មកុមារ, និង (៥) ទេសន្តរប្រវេសន៍ការងារ
- បានដាក់ឱ្យដំណើរការប្រអប់បណ្តឹងអនាមិកសម្រាប់ទទួលបណ្តឹងនានាពីសាធារណជនតាមរយៈគេហទំព័រ https://feedback.mlvt.gov.kh ឬ QR code ដោយបានទទួលបណ្តឹងអនាមិកសរុបចំនួន ៣៦៤បណ្តឹង ដែលក្នុងនោះមានបណ្តឹងពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ ចំនួន ១៥២ករណី, ហត្ថពលកម្មបរទេស ចំនួន ១៣ករណី, ទេសន្តរប្រវេសន៍ការងារ ចំនួន ៥ករណី, របបសន្តិសុខសង្គម ចំនួន ៧៩ករណី, និងការផ្តល់សេវារបស់ក្រសួង ចំនួន ១៩ករណី

“បណ្តឹងអនាមិក”

- បានចូលរួមលើកកម្ពស់សមភាពយេនឌ័រ ដោយខិតខំអនុវត្តប្រកបដោយជោគជ័យស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១២ចំណុច របស់ **សម្តេចតេជោ ហ៊ុន សែន** និងផែនការយុទ្ធសាស្ត្រនារីរតនៈ និងបានផ្សព្វផ្សាយអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ
- បានចូលរួមអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ដើម្បីឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់និយោជក និងកម្មករនិយោជិត តាមរយៈការបង្កើតការផ្តល់សេវាឱ្យទៅកៀកជិតអ្នកប្រើប្រាស់សេវា ដោយបានធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនរដ្ឋបាលរាជធានី ខេត្ត ចំនួន ៩សេវា តាមរយៈអនុក្រឹត្យលេខ៣១៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនរដ្ឋបាលរាជធានី ខេត្ត
- បានបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានបន្តពង្រឹងកិច្ចសហការល្អជាមួយដៃគូ ការពារផលប្រយោជន៍ និងលើកកម្ពស់កិត្យានុភាពកម្ពុជានៅលើវេទិកាតំបន់ និងអន្តរជាតិ ដូចជា អាស៊ាន អង្គការអន្តរជាតិខាងការងារ ក្រុមប្រឹក្សាសិទ្ធិមនុស្ស យន្តការពិនិត្យជាសកលតាមកាលកំណត់ គណៈកម្មការទទួលបន្ទុកអនុសញ្ញាសិទ្ធិមនុស្ស និងសហភាពអឺរ៉ុប
- បានចូលរួមលើកកម្ពស់សមភាពយេនឌ័រ និងចូលរួមយ៉ាងសកម្មក្នុងការងារសេវាសង្គម ដូចជាជួយលើកកម្ពស់ឱកាសការងារដល់ជនមានពិការភាព ការប្រយុទ្ធប្រឆាំងការប្រើប្រាស់ថង់ប្លាស្ទិក និងយុទ្ធនាការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀននៅកន្លែងធ្វើការ។

## II- ទិសដៅអនុវត្តបន្តឆ្នាំ២០២៥

១. បន្តពង្រឹងនិងពង្រីកសេវាស្វែងរកការងារ តាមរយៈការបន្តបង្កើតមជ្ឈមណ្ឌលការងារចល័តរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារនៅតាមមូលដ្ឋាននិងទីប្រជុំជន និងបញ្ចូលសេវាសាធារណៈចល័ត, ការបង្កើនការផ្តល់សេវាប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈនៅតាមបណ្តាគ្រឹះស្ថានមធ្យមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា និងផលិតព្រឹត្តិបត្រទស្សនវិស័យមុខរបរ និងការងារ ដែលអាចផ្តល់ព័ត៌មានអំពីតម្រូវការជំនាញនិងការងារសម្រាប់សិស្ស និស្សិត យុវជន ក៏ដូចជាក្រសួងដែលជាមូលដ្ឋានក្នុងការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម សំដៅបង្កើតទីផ្សារការងារមួយដែលមានភាពរឹងមាំ និងជវភាព។

២. បន្តរៀបចំ ផលិត និងផ្សព្វផ្សាយរបាយការណ៍អង្កេត និងឯកសារសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងទីផ្សារការងារឱ្យបានទៀងទាត់ ដើម្បីផ្តល់ព័ត៌មានទីផ្សារការងារឱ្យបានគ្រប់ជ្រុងជ្រោយ ដល់អ្នកស្វែងរកការងារ កម្មករនិយោជិត និយោជក អ្នកផ្តល់ការបណ្តុះបណ្តាល និងសាធារណជន។

៣. បន្តអនុវត្តឱ្យជោគជ័យនូវការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ចំនួន ១,៥លាននាក់ ប្រកបដោយគុណភាពស្របតាមអភិក្រម "**រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ**" តាមរយៈការសហការយ៉ាងស្អិតរមួតជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត និងដៃគូពាក់ព័ន្ធ ដើម្បីបង្កើនការចុះឈ្មោះចូលរៀនឱ្យបានច្រើន និងពិនិត្យមើលឡើងវិញលើមុខជំនាញ សម្រាប់បណ្តុះបណ្តាលឱ្យមានលក្ខណៈសមស្របទៅនឹងតម្រូវការជាក់ស្តែងនៃទីផ្សារការងារ និងភាពប្រទាក់ក្រឡាជាមួយស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់គ្រួសារក្រីក្រ។

៤. បន្តជំរុញការវាយតម្លៃទទួលស្គាល់ការសិក្សាដែលមានពីមុន (Recognition of Prior Learning - RPL) និងការធ្វើតេស្តទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន (Recognition of Current Competence - RCC) ដើម្បីឱ្យមានការទទួលស្គាល់សមត្ថភាព និងជំនាញច្បាស់លាស់ និងជាច្រកមួយដែលបត់បែនបានលឿនក្នុងការធ្វើតេស្តសមត្ថភាព និងជំនាញក្នុងការទាញយកបាននូវសន្និធិជំនាញនៅកម្ពុជា ក្នុងការឆ្លើយតបតម្រូវការឧស្សាហកម្មសម្រាប់បង្កើនផលិតភាពនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

៥. បន្តពង្រឹងការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងធានាគុណភាពនៃការបណ្តុះបណ្តាលដោយសហការជាមួយដៃគូឯកជន ពង្រឹងប្រសិទ្ធភាពនៃកម្មវិធីការសិក្សាផ្អែកលើការងារ (Work Based Learning) និងបន្តការជំរុញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងស្របតាមច្បាប់ស្តីពីការងារ តាមរយៈការពិនិត្យលទ្ធភាព ក្នុងការទទួលយកសិស្សចូលហាត់ការ និងកម្មសិក្សាក្នុងសហគ្រាស គ្រឹះស្ថាន ដើម្បីអាចរាប់បញ្ចូលជាការបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង។ ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងប្រកបដោយភាពបត់បែន (Apprenticeship Program) និងផ្តល់ជម្រើសសម្រាប់សហគ្រាស គ្រឹះស្ថាន ដែលបង្កលក្ខខណ្ឌងាយស្រួលក្នុងការចូលរួមអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ជាមួយសហគ្រាស គ្រឹះស្ថានលើការរៀនផងធ្វើការផង រួមជាមួយការចុះកម្មសិក្សាក្រោយបញ្ចប់ការសិក្សានៅគ្រឹះស្ថានបណ្តុះបណ្តាល។

៦. ត្រូវបន្តពង្រឹងការអនុវត្តច្បាប់ និងលើកកម្ពស់អត្រាអនុលោមភាពតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានពាក់ព័ន្ធ តាមរយៈការពង្រឹងយន្តការអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យអធិការកិច្ចការងារ និងក្រុមអធិការកិច្ចអន្តរក្រសួង ដោយត្រូវចុះអធិការកិច្ចក្នុង ១ឆ្នាំ តែ ១ដងគត់ លើគោលដៅតែមួយ ទៅតាមការចាំបាច់ និងតាមការជ្រើសរើស លើកលែងតែមានបណ្តឹងពីបងប្អូនកម្មករនិយោជិត ឬមានឧបទ្ទវហេតុណាមួយកើតឡើង។ ជាមួយគ្នានេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដឹកនាំការធ្វើអធិការកិច្ចអន្តរក្រសួង ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ជាពិសេសក្នុងវិស័យដែលមានហានិភ័យខ្ពស់។

៧. បន្តលើកកម្ពស់ជីវភាពកម្មករ និយោជិត តាមរយៈយន្តការចរចាកំណត់ប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំ

៨. បន្តលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ និងជំរុញយុទ្ធនាការថ្នាក់ជាតិស្តីពី "**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**" និងបង្កើនប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ តាមរយៈការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សាវិវាទការងារ ឱ្យក្លាយជាស្ថាប័នមានវិជ្ជាជីវៈ និងទទួលបានការជឿជាក់ពីសាធារណជន។

៩. បន្តលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់បងប្អូនកម្មករនិយោជិតនៅកន្លែងធ្វើការ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តពង្រឹងការអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ (OSH) នៅកន្លែងធ្វើការ ទាំងនៅក្នុងវិស័យកម្មន្តសាល សេវាកម្សាន្ត និងសំណង់ ឱ្យបានកាន់តែល្អប្រសើរ កាត់បន្ថយឱ្យបានជាអតិបរមានូវបញ្ហាគ្រោះថ្នាក់ការងារ និងហានិភ័យនានា។

១០. បន្តពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព ជំរុញការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីនីតិវិធីនៃការចេញទៅធ្វើការនៅបរទេសដោយសុវត្ថិភាព ចៀសវាងការចាញ់បោកមេខ្យល់ និងបង្កើតឱ្យមានទំនាក់ទំនងជាសហគមន៍រវាងឪពុកម្តាយ និងកូនដែលចេញទៅធ្វើការនៅបរទេស និងការពង្រឹងការគ្រប់គ្រងហត្ថពលកម្មជនបរទេសដែលមកធ្វើការនៅប្រទេសកម្ពុជា ដោយធ្វើការណែនាំពន្យល់ឱ្យបានច្បាស់លាស់ ចៀសវាងធ្លាក់ចូលក្នុងការជួញដូរមនុស្ស ឬការធ្វើការដោយខុសច្បាប់នៅប្រទេសកម្ពុជា។

១១. បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពនៃសេវា ប.ស.ស. តាមរយៈការបន្តកែលម្អការផ្តល់សេវា និងការយកចិត្តទុកដាក់បន្ថែមលើសមាជិក ប.ស.ស., ការទូទាត់ថ្លៃសេវា, និងយន្តការនៃការទទួលពាក្យបណ្តឹងតាមប្រអប់បណ្តឹងអនាមិក នៅពេលសមាជិក ប.ស.ស. បានជួប ឬឃើញនូវភាពមិនប្រក្រតីណាមួយ, ការពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យសមាជិក ប.ស.ស. ឱ្យមានភាពប្រទាក់ក្រឡាគ្នា ព្រមជាមួយការពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការការងាររបស់ ប.ស.ស. ឱ្យស្របទៅតាមកំណើត និងទំហំនៃសមាជិកដែលមានការកើនឡើងខ្ពស់ នារយៈពេលចុងក្រោយនេះ។

១២. បន្តរៀបចំការផ្តល់សេវានានារបស់ក្រសួងតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយរៀបចំឱ្យមាន សៀវភៅណែនាំសម្រាប់ការប្រើប្រាស់ ដើម្បីឱ្យអ្នកប្រើប្រាស់បានយល់ និងងាយស្រួលប្រើប្រាស់សេវារបស់ក្រសួង និងត្រូវធ្វើការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលបានការធ្វើប្រតិភូកម្ម ដើម្បីអាចប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះកាន់តែមានប្រសិទ្ធភាព និងមានភាពប្រទាក់ក្រឡាគ្នាស្របទៅតាមការធ្វើប្រតិភូកម្មដែលបានបែងចែករវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

១៣.បន្តយកចិត្តទុកដាក់ចូលរួមអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈវិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការបន្តពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងគ្រប់ជាន់ថ្នាក់ឱ្យកាន់តែមានសមត្ថភាពក្នុងការបំពេញការងារឱ្យកាន់តែមានភាពបុរេសកម្ម, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយពាក់ព័ន្ធ និងការធ្វើបរិវត្តកម្មឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ ឆ្លើយតបនឹងសំណូមពររបស់កម្មករនិយោជិតវិស័យឯកជន និងសាធារណជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥